Student/Registration Number | | | | | | | | | | | | Centre Number | | | | | | |

## 2020 PUBLIC EXAMINATION

# Khmer

## Continuers Level

**Tuesday 20 October: 2 pm Australian Eastern Daylight Time**

Reading Time: 10 minutes
Writing Time: 2 hours and 30 minutes

- *You have 10 minutes to read all the papers and to familiarise yourself with the requirements of the questions. You MUST NOT write during this time.*
- *Monolingual and/or bilingual printed dictionaries may be consulted during the reading time and also during the examination.*

## Section 1: Listening and Responding (30 marks)

**Instructions to Students**

1. Allow approximately 40 minutes for Section 1.

2. Write all your answers to the questions in Section 1 in this booklet using black or blue pen. Space is provided for you to make notes.

3. You must answer ALL questions in Part A and Part B.

4. Answer Part A in ENGLISH and Part B in KHMER.

5. Write your student/registration number and the centre number (if required) on the front cover of this booklet.

6. All question booklets will be collected at the end of the examination.

© SACE Board of South Australia 2020

**Part A** (Questions 1 to 3)
(15 marks)

---

*Your response will be assessed on how well you:*

- *understand general and specific aspects of texts by identifying and analysing information and convey the information accurately and appropriately.*

---

You will hear THREE texts. Each text will be played twice. There will be a short break between the first and second playings of each text. You may make notes at any time.

Listen carefully to each text and then answer the questions in ENGLISH.

| | **Marks** | You may make notes in this space. These notes will NOT be assessed. |
|---|---|---|
| **Text 1** | | |
| 1. Compare the Cambodian school system during the current regime with the school system during the French protectorate regime. | **3** | |

______________________________________________________________________

______________________________________________________________________

______________________________________________________________________

______________________________________________________________________

______________________________________________________________________

______________________________________________________________________

______________________________________________________________________

______________________________________________________________________

______________________________________________________________________

Marks

You may make notes in this space. These notes will NOT be assessed.

**Text 2**

2. (a) Why is the mother opposed to granting her son’s request at first? **3**

_______________________________________________________________

_______________________________________________________________

_______________________________________________________________

_______________________________________________________________

_______________________________________________________________

_______________________________________________________________

_______________________________________________________________

_______________________________________________________________

_______________________________________________________________

(b) What is the meaning of ‘ណ្ហើយ មានក៏មានទៅអោយវាគ្រប់គ្រឿងតែម្តងទៅ។’ and how is it relevant to the conversation? **3**

_______________________________________________________________

_______________________________________________________________

_______________________________________________________________

_______________________________________________________________

_______________________________________________________________

_______________________________________________________________

_______________________________________________________________

Marks

You may make notes in this space. These notes will NOT be assessed.

**Text 3**

3. (a) Who is Mr Soknat? **2**

(b) What makes the *Khleing Ek* so special? **4**

**Part B** (Questions 4 to 6)
(15 marks)

---

*Your response will be assessed on how well you:*

- *understand general and specific aspects of texts by identifying and analysing information and convey the information accurately and appropriately.*

---

You will hear THREE texts. Each text will be played twice. There will be a short break between the first and second playings of each text. You may make notes at any time.

Listen carefully to each text and then answer the questions in KHMER.

**Marks**

You may make notes in this space. These notes will NOT be assessed.

**Text 4**

4. (a) Explain how the snail outsmarted the lion. **2**

ចូរពន្យល់ថាតើខ្យងឆ្លាតជាងតោយ៉ាងដូចម្តេច។

___

___

___

___

___

___

(b) Why was the lion ashamed? **3**

ហេតុដូចម្តេចបានជាតោអាម៉ាស់មុខ?

___

___

___

___

___

___

___

___

___

Marks

You may make notes in this space. These notes will NOT be assessed.

**Text 5**

5. (a) What event is taking place? **1**

តើព្រឹត្តិការណ៍អ្វីដែលកំពុងកើតឡើង?

(b) Explain how this event is being celebrated. **4**

ចូរពន្យល់ថាតើគេអបអរសាទរព្រឹត្តិការណ៍នេះយ៉ាងដូចម្តេចខ្លះ។

**Marks**

You may make notes in this space. These notes will NOT be assessed.

**Text 6**

6. (a) Explain how Mr Ponn supports his clients. **2**

ចូរពន្យល់ថាតើលោកប៉ុនជួយអតិថិជនរបស់គាត់ដោយរបៀបណា។

(b) What are the difficulties facing elderly Khmer people in Australia, according to Mr Ponn? **3**

បើយោលទៅតាមលោកប៉ុន តើមនុស្សចាស់ជរាខ្មែរនៅប្រទេសអូស្ត្រាលីប្រឈមមុខនឹងឧបស័គ្គអ្វីខ្លះ?

**End of Section 1**

**KHMER (CONTINUERS) EXAMINATION 2020**

**Section 1: Listening and Responding**

## PART A

### *Text 1*

<Male speaker>

ថ្ងៃនេះខ្ញុំនឹងនិយាយអំពីការបង្រៀននៅសាលានៃប្រទេសកម្ពុជា។
ក្នុងរយៈពេលមួយសតវត្សចុងក្រោយនេះ ប្រទេសកម្ពុជាមានរបបនយោបាយជាច្រើន។
ក្នុងរបបអនានិគមបារាំង
សិស្សត្រូវបានគេបង្រៀនគ្រប់មុខវិជ្ជាជាភាសាបារាំងលើកលែងតែភាសាខ្មែរ។
ក្រោយពីពេលនេះមក
រាជរដ្ឋាភិបាលកម្ពុជាបានប្ដូរប្រព័ន្ធសិក្សាបន្តិចម្ដងៗមកបង្រៀនគ្រប់មុខវិជ្ជាជាភាសាខ្មែរវិញ។
នៅក្នុងរបបសព្វថ្ងៃ សិស្សក្នុងសាលារដ្ឋរៀនគ្រប់មុខវិជ្ជាជាភាសាខ្មែរ។ ទោះជាយ៉ាងណាក្ដី
ក្នុងសាលាឯកជនភាគច្រើន ភាសាបរទេសនៅតែច្រើនប្រើជាយានសម្រាប់បង្រៀនដដែល។

<0:44 mins>

***Text 2***

<Male> កូន ម៉ាក់ ខ្ញុំសូមសួរបន្តិចបានទេ?

<Female> ម្ដាយ កុំប្រាប់ម៉ាក់ថាឯងចង់បានលុយបន្ថែមណ៎ា។

កូន ទេម៉ាក់ ខ្ញុំសុំចិញ្ចឹមចាបមួយគូបានទេ?

ម្ដាយ ទេ ទេ ទេ ឯងមិនអាចចិញ្ចឹមចាបទេ។

កូន ហេតុអីទៅម៉ាក់ យើងមានឆ្កែ ឆ្មា និងត្រី ម៉េចក៏ចាបមិនបាន?

ម្ដាយ យើងចិញ្ចឹមសត្វគ្រប់គ្រាន់ហើយ! ហើយមានតែម៉ាក់ទេដែលមើលថែវាទាំងនោះ។
ម៉្យាងទៀត វាឃោឃៅណាស់ដែលទុកចាបក្នុងទ្រុង។
តើឯងសប្បាយចិត្តទេបើឯងរស់នៅក្នុងទ្រុងនៅជាតិក្រោយ។

កូន ម៉ាក់ ខ្ញុំមិនជឿថាមានជាតិក្រោយទេ។ ណ៎ាម៉ាក់ណ៎ា! ខ្ញុំសន្យាថានឹងមើលថែវាខ្លួនឯង។ ហើយខ្ញុំនឹងខំរៀនយ៉ាងខ្លាំងថែមទៀត។

ម៉ាក់ ក្នុងករណីនេះ ឯងអាចចិញ្ចឹមចាបមួយគូបាន។
ឯងត្រូវតែបញ្ជាក់ថាឯងអាចមើលថែវាខ្លួនឯងបានមុននឹងចិញ្ចឹមច្រើនថែមទៀត។
ហើយម៉្យាងទៀត ប៉ាឯងត្រូវតែសង់ទ្រុងធំមួយសម្រាប់វាជាមុនសិន។

កូន ខ្ញុំប្រាកដថាប៉ានឹងសង់ទ្រុងដ៏ធំនិងមាំមួយអោយខ្ញុំព្រោះគាត់ក៏ចូលចិត្តចាបដែរ។

ម្ដាយ អ្ហឹម! ដូចឪពុកដូចកូនដល់ហើយណ្ហ៎។ ណ្ហើយ
មានក៏មានទៅអោយវាគ្រប់គ្រឿងតែម្ដងទៅ។

កូន អរគុណម៉ាក់! ខ្ញុំដឹងថាម៉ាក់នឹងយល់ព្រម។ ខ្ញុំស្រឡាញ់ម៉ាក់ណាស់។

<1:20 mins>

*Text 3*

<Female> អ្នកសំភាស ថ្ងៃនេះក្នុងស្ទូឌីយូរបស់យើង យើងមានភ្ញៀវកិត្តិយសម្នាក់មកពីប្រទេសកម្ពុជា គឺលោកសុខណាតដែលជាអ្នកដឹកនាំក្រុមខ្មែរមកចូលប្រកួតប្រជែងជាអន្តរជាតិខាងបង្ហោះខ្លែងនៅដាវិន។ ជំរាបសួរ!

<Male> សុខណាត បាទ ជំរាបសួរ!

អ្នកសំភាស

តើប៉ុន្មានលើកហើយដែលប្រទេសកម្ពុជាបានមកចូលរួមប្រកួតជាអន្តរជាតិខាងបង្ហោះខ្លែង?

សុខណាត ពីរលើកហើយនៅបារាំងនិងអ៊ីតាលី។
យើងមានសំណាងណាស់ដែលបានអង្គការមនុស្សធម៌អន្តរជាតិមួយធានាយើងអោយមកចូលរួមប្រកួតជាអន្តរជាតិនៅទីនេះ
ជាលើកទីបី។

អ្នកសំភាស អុំហ ល្អណាស់! តើលោកជឿថាខ្លែងខ្មែរអាចឈ្នះគេទេលើកនេះ?
ហើយដោយសារអ្វី?

សុខណាត បាទ
លើកនេះយើងមានសំណាងច្រើននឹងឈ្នះពីព្រោះខ្លែងរបស់យើងជាខ្លែងចាស់បុរាណ ហើយខុសពីគេ។ វាស្អាត សង្ហា ហើយសំខាន់ជាងគេនោះ
វាអាចបញ្ចេញសំឡេងយ៉ាងខ្លាំងពេលវាហោះ។ ខ្លែងនេះមានឈ្មោះថា ខ្លែងឯក។

អ្នកសំភាស តើខ្លែងឯកកំពុងពេញនិយមទេនៅកម្ពុជា?

សុខណាត ឥឡូវណេះអត់ទេ ពីព្រោះវាពិបាកធ្វើពេក។ គេត្រូវមានអំណត់ធ្មត់ ប្តូរផ្តាច់ធ្វើ និងត្រូវមានបច្ចេកទេសផងដើម្បីធ្វើបានជោគជ័យ
ហើយយើងមិនមានកំណត់ត្រានៃរបៀបធ្វើទេ។ ក្នុងអំឡុង៧០ឆ្នាំកន្លងទៅនេះ
មិនមានមនុស្សច្រើនទេដែលធ្លាប់បានឃើញឬឮសំឡេងខ្លែងឯក។

អ្នកសំភាស តើលោកគ្រោងថែរក្សាទំនៀមទំលាប់ដ៏សំខាន់នេះយ៉ាងណាដែរ?

សុខណាត

យើងមានសំណាងណាស់ដែលក្រសួងអភិរក្សវប្បធម៌បានសម្រេចចិត្តធ្វើការស្រាវ

ជ្រាវប្រវត្តិនៃខ្លែងនេះ ដើម្បីយើងអាចទុកវាជាកេរ្តិ៍មរតកដល់ក្មេងជំនាន់
ក្រោយ។

<1:45 mins>

ជ្រាវប្រវត្តិនៃខ្លែងនេះ ដើម្បីយើងអាចទុកវាជាកេរ្តិ៍មរតកដល់ក្មេងជំនាន់
ក្រោយ។

**PART B**

***Text 4***

<Female speaker>

ថ្ងៃនេះយាយនឹងនិយាយរឿងល្បើកមួយ។

កាលពីព្រេងនាយមានតោមួយមកផឹកទឹកបឹងមួយនៅក្នុងព្រៃ។ ហេតុអីបានជាឯងផឹកទឹកខ្ញុំ? ខ្យងសួរតោ។ តោក៏គ្រហឹមយ៉ាងខ្លាំងថា៖ ទឹកនេះជារបស់អញ។ អញជាស្តេចព្រៃ អាសត្វតូចច្រមក់!។ ខ្យងក៏តបវិញថា៖ បញ្ជាក់ទៅមើល ថាឯងអាចរត់ប្រណាំងឈ្នះខ្ញុំជុំវិញបឹងនេះ។ វាទាំងពីរក៏ចាប់រត់ប្រណាំងគ្នា។ រត់បានមួយជុំ តោស្រែកថា៖ អ្ហែងនៅឯណា?។ ខ្យងក៏ប្រាប់ទៅមិត្តវាម្នាក់អោយងើបពីទឹកនៅពីមុខតោ រួចឆ្លើយថា៖ ខ្ញុំនៅឯណេះ។ តោខឹងខ្លាំងពេកក៏ខំរត់លឿនឡើងៗរហូតដល់វាមានរបួស ហើយដើរចេញយ៉ាងអាម៉ាស់មុខ។

<0:44 mins>

*Text 5*

<Male speaker>

ពេលនេះខ្ញុំកំពុងឈរខាងក្រៅវិទ្យាល័យថ្មីមួយនៅតំបន់ដាច់ស្រយាលមួយក្នុងខេត្តតាកែវ។ វាប្រាកដជាថ្ងៃដ៏ពិសេសមួយសម្រាប់ប្រជាជនខ្មែរដែលរស់ក្នុងតំបន់ដាច់ឆ្ងាយពីគេនេះ។

វិទ្យាល័យថ្មីនេះជាជំនួយរបស់រាជរដ្ឋាភិបាលប្រទេសជប៉ុន ហើយវាត្រូវបានគេសម្ពោធនៅថ្ងៃនេះ។

ធាតុអាកាសក្តៅហើយស្អិតមិនបានរារាំងមនុស្សដ៏ច្រើនកុះករមកជួបជុំគ្នាថ្ងៃនេះទេ។

យើងឃើញមានសិស្សជាច្រើននាក់ ស្លៀកពាក់ឯកសណ្ឋានសាលា ដែលដឹកនាំដោយមាតាបិតានិងលោកគ្រូអ្នកគ្រូរបស់គេ។

រោងដ៏វែងធ្វើអំពីឫស្សីដែលមនុស្សកំពុងអង្គុយរង់ចាំយ៉ាងតក់ក្រហល់មានតុបតែងដោយផ្កាធាងដូង និងទង់ជាតិទាំងពីរប្រទេស។

បើសិនជាយើងក្រឡេកមើលទៅលើ យើងឃើញមានបដាមួយចំនួនសរសេរថាៈជ័យោ! មិត្តភាពខ្មែរ-ជប៉ុន និងជ័យោ! រាជរដ្ឋាភិបាលកម្ពុជា។

ឥឡូវនេះយើងកំពុងរង់ចាំការអញ្ជើញមកដល់នៃអភិបាលខេត្តតាកែវដែលលោកនឹងប្រកាសបើកសាលាអោយប្រើប្រាស់។ បន្ទាប់មកនឹងមានរបាំជូនពរសំដែងដោយសិស្សសាលា។

សាលាថ្មីនេះវានឹងនាំមកនូវប្រយោជន៍យ៉ាងធំធេងដល់សហគមន៍ដ៏តូចមួយនេះ។
យើងអាចដឹងបានដោយសារបានឃើញសេចក្តីរំភើបរបស់ប្រជាជនក្នុងថ្ងៃនេះ។
សិស្សសាលាក្នុងភូមិនេះនឹងមិនចាំបាច់ធ្វើដំណើរ៣០គីឡូម៉ែត្រដើម្បីបន្តការសិក្សារបស់គេទេ។
នេះបានចំជាថ្ងៃដ៏មហោឡារឹក
មែន!

<1:40 mins>

*Text 6*

<Female> អ្នកសំភាស	ជំរាបសួរលោកប៊ុន។ តើលោកមានមុខងារជាអ្វីក្នុងឋានៈជាអ្នកបម្រើសហគមន៍?

<Male> ប៊ុន	បាទ ជំរាបសួរ។ ខ្ញុំជាបុគ្គលិកសមាគមខ្មែរអូស្រ្តាលីបម្រើខាងផ្នែកចាស់ជរា។

អ្នកសំភាស	តើលោកផ្សាយសេវាកម្មរបស់លោកដោយរបៀបណា?

ប៊ុន	ខ្ញុំចុះផ្សាយសេវាកម្មរបស់ខ្ញុំក្នុងព្រឹត្តិប័ត្រសមាគម ផ្សាយដំណឹងក្នុងកម្មវិធីវិទ្យុសហគមន៍ និងខ្ញុំតែងតែបង្ហាញខ្លួនខ្ញុំផ្ទាល់ និងផ្សាយសេវាកម្មរបស់ខ្ញុំនៅរាល់ពេលដែលមានពិធីបុណ្យព្រះពុទ្ធសាសនាម្តងៗ។

អ្នកសំភាស	តើកិច្ចការរបស់លោកមានអ្វីខ្លះ?

ប៊ុន	កិច្ចការរបស់ខ្ញុំគឺជួយបកប្រែភាសាផ្ទាល់មាត់ និងបកប្រែឯកសាររដ្ឋនានា ផ្តល់កិច្ចបម្រើដល់គ្រួសារដែលត្រូវការជំនួយ ជួយដាក់ពាក្យសុំផ្ទះក្នុងមណ្ឌលចាស់ជរា និងជំនួយដទៃទៀតដែលគេត្រូវការ។

អ្នកសំភាស	ជាទូទៅ តើចាស់ជរាខ្មែរចូលចិត្តរស់នៅក្នុងមណ្ឌលចាស់ជរាទេ? ព្រោះអ្វី?

ប៊ុន	ទេ អត់ទាល់តែសោះ គាត់នឹងទៅបើសិនជាគាត់ត្រូវតែទៅ។ តាមពិត គាត់មិនចេះនិយាយភាសា មិនចូលចិត្តទទួលទានម្ហូបអឺរ៉ុប និងមិនមានចំណូលចិត្តដូចគ្នានឹងអ្នករស់នៅក្នុងមណ្ឌលចាស់ជរាទេ។ ទាំងនេះធ្វើអោយគាត់មានអារម្មណ៍ឯកោតែឯង ហើយសំខាន់ជាងនេះទៅទៀត គាត់ធ្លាប់តែរស់នៅជុំគ្នាជាចង្កោមគ្រួសារ។

អ្នកសំភាស	តើគាត់ចូលចិត្តរស់នៅដោយខ្លួនឯងជាជាងរស់នៅក្នុងមណ្ឌលចាស់ជរាទេ?

ប៊ុន	នោះក៏អត់ដែរ មនុស្សជំនាន់នេះចូលចិត្តរស់ជាមួយកូនចៅរបស់គេ។

<1:42 mins>

Student/Registration Number | | | | | | | | | | | Centre Number | | | | | |

## 2020 PUBLIC EXAMINATION

# Khmer

## Continuers Level

## Section 2: Reading and Responding (25 marks)

**Instructions to Students**

1. Allow approximately 1 hour and 10 minutes for Section 2.
2. Write all your answers to the questions in Section 2 in this booklet using black or blue pen. Space is provided for you to make notes.
3. You must answer ALL questions in Part A and Part B.
4. Answer Part A in ENGLISH and Part B in KHMER.
5. Write your student/registration number and the centre number (if required) on the front cover of this booklet.
6. All question booklets will be collected at the end of the examination.

*© SACE Board of South Australia 2020*

**Part A** (Questions 7 and 8)
(10 marks)

---

*Your response will be assessed on how well you:*

- *understand general and specific aspects of texts (for example, by comparing, contrasting, summarising, and/or evaluating) and convey the information appropriately.*

---

7. Read the text and then answer in ENGLISH the questions that follow.

### កីឡាសម្រាប់សុខភាពល្អ

ជាប្រវត្តិសាស្ត្រ ប្រជាជនខ្មែរជាច្រើនតែងចាត់ទុកកីឡា ដូចជាបាល់ទាត់ បាល់បោះឬបាល់ទះថាគ្រាន់តែជាសម្រាប់ប្រកួតប្រជែងជាជាងសម្រាប់ការសប្បាយរីករាយ។

មកទល់នឹងឆ្នាំ១៩៧៥ មុនចាប់ផ្តើមរបបកុម្មុយនិស យើងមានកម្មវិធីសិក្សាកីឡាក្នុងសាលារៀន ប៉ុន្តែមិនមានខ្មែរច្រើននាក់ទេដែលសកម្មក្នុងការលេងកីឡាឬធ្វើលំហាត់ប្រាណក្នុងពេលទំនេររបស់គេទេ។ យុវជនខ្មែរច្រើននាក់ណាស់បានបន្តលេងកីឡាគឺដោយសារតែគេមានដុងខាងកីឡាណាមួយ ហើយសង្ឃឹមថាថ្ងៃណាមួយក្តីស្រម័យលេងកីឡាជាអាជីពរបស់គេនឹងក្លាយជាការពិត។ មនុស្សវ័យកណ្តាលភាគច្រើនរវល់តែធ្វើការងារ ដូច្នេះហើយគេមិនមានពេលគ្រប់គ្រាន់សម្រាប់លេងកីឡាទេ។ អ្នកណាក៏មិនដែលបានឃើញមានមនុស្ស ហាត់ប្រាណនៅតាមកន្លែងទីសាធារណៈឡើយ។ ទោះបីជាយ៉ាងនេះក្តី ប្រជាជនខ្មែរច្រើនណាស់មានរាងតូចច្រឡឹងនិងមានសុខភាពល្អ នេះប្រហែលជាមកពីប្រភេទម្ហូបដែលគេបរិភោគនិងកិច្ចការប្រើកំឡាំងបាយដែលគេបានធ្វើ។

អ្វីៗបានផ្លាស់ប្តូរច្រើនមែនទែនក្នុងសម័យនេះ ជាពិសេសចំពោះប្រជាជនដែលរស់នៅក្នុងទីក្រុង។ ដោយសារតែមានឥទ្ធិពលពីការផ្សាយពាណិជ្ជកម្ម គេទាំងឡាយបរិភោគ ជក់និងផឹកគ្រឿងស្រវឹងច្រើនជាងមុន។ អញ្ចឹងហើយបានជាឥឡូវណោះមានខ្មែរច្រើននាក់ណាស់ដែលលើសទំងន់ ឬមានក្បាលពោះធំ។ កាលពីជំនាន់ដើម គេយល់ថាមនុស្សមានក្បាលពោះធំជាមនុស្សអ្នកមាន ប៉ុន្តែឥឡូវណោះមិនដូច្នោះទេ។ ការនេះបានជំរុញអោយខ្មែរកាន់តែច្រើននាក់ចាប់ផ្តើមគិតគូពីសុខភាពរបស់ខ្លួន។ ឥឡូវណោះមនុស្សគ្រប់ស្រទាប់ច្រើនជួបជុំគ្នានៅទីធ្លាសាធារណៈដើម្បីហាត់ប្រាណដូចជារត់ ហាត់*ថាយឈី* និងរាំ។ អ្នកខ្លះទៅហាត់*អារ៉ូប៊ិច*ឬចូលក្លឹបកីឡា។ ឥឡូវណោះមនុស្សបានបែទៅរកកីឡា ដែលកាលពីដើមគេចាត់ទុកវាជាការមិនសំខាន់ ពីព្រោះគេទាំងឡាយមានអារម្មណ៍ថាកីឡាជាការល្អសម្រាប់សុខភាពរបស់គេ។

QUESTION

**Marks**

Explain how the attitude of Khmer people towards sport has changed in the last few decades. Support your answer with evidence from the text. **6**



PLEASE TURN OVER

8. Read the text and then answer in ENGLISH the questions that follow.

១៤ មេសា ២០២០

យប់មិញខ្ញុំដេកមិនសូវលក់សោះព្រោះខ្ញុំរំភើបខ្លាំងពេក។ ពេលខ្ញុំភ្ញាក់ពីដេក ម៉ោងទើបតែ៥ព្រឹកប៉ុណ្ណោះ មានថ្ងៃរះរួចបាត់ទៅហើយ។ ទីក្រុងភ្នំពេញទាំងមូលនៅតែមានសភាពស្ងប់ស្ងាត់នៅឡើយ។ ប៉ុន្តែកន្លះម៉ោងក្រោយមក ខ្ញុំអាចលឺសូរសំឡេងក្ដុងក្ដាំងបន្លឺពីផ្លូវថ្នល់ក្រោមបន្ទប់ខ្ញុំនៃផ្ទះសំណាក់មួយ។ ខ្ញុំឆ្ងល់ថាតើនេះវាជាសំឡេងអ្វីទៅ? ខ្ញុំក៏រត់យ៉ាងលឿនចុះទៅក្រោមដើម្បីរកមើលថាតើវាមានហេតុការអី។ ខ្ញុំក្រឡេកមើលតាមកញ្ចក់បង្អួចក៏ឃើញមានមនុស្សជាច្រើនខ្លះដើរ ខ្លះជិះម៉ូតូ ឬជិះស៊ីក្លូចុះឡើងៗនៅមុខផ្ទះសំណាក់។ ខ្លះទូលឥវ៉ាន់នៅលើក្បាល ឬរែកឥវ៉ាន់នៅលើស្មាដើម្បីយកទៅលក់នៅផ្សារជិតនេះ។ ខ្លះទៀតរុញរទេះឃីតៗលក់ផ្លែឈើគ្រប់មុខតាមចិញ្ចើមថ្នល់ ដោយពពាយនាយយ៉ាងខ្លាំងទៅសាធារណជន។ នៅខាងក្រោមផ្ទះ ខ្ញុំបានឃើញម្ចាស់ផ្ទះសំណាក់ចាប់បើកទ្វារហាងទំនិញរបស់គាត់ បោសសំអាតហាង និងរៀបចំទំនិញសម្រាប់លក់ ហើយជួនកាលគាត់បានស្រែកហៅកូនចៅរបស់គាត់អោយមកជួយ។ ក្រោយមកខ្ញុំបានលឺសូរសំឡេងកូនង៉ាយំនៅបន្ទប់ជាប់ខ្ញុំ។នេះជាចំណាប់អារម្មណ៍ដំបូងបង្អស់របស់ខ្ញុំនៃទីក្រុងភ្នំពេញ។ ខ្ញុំមានការរំភើបយ៉ាងខ្លាំង ហើយខ្ញុំចង់ដឹងបន្ថែមទៀតពីទីក្រុងនេះ។ ខ្ញុំខានបានជួបប្រទះភាពសកម្មនិងភាពរស់រវើកនៃបរិយាកាសយ៉ាងនេះអស់ចំនួន២០ឆ្នាំហើយ។

សុជាតី

QUESTIONS

**Marks**

(a) What did Socheatey experience when she woke up? **2**

______________________________________________________________________

______________________________________________________________________

______________________________________________________________________

______________________________________________________________________

______________________________________________________________________

______________________________________________________________________

(b) How does Socheatey feel about Phnom Penh? Support your answer with evidence from the text. **2**

______________________________________________________________________

______________________________________________________________________

______________________________________________________________________

______________________________________________________________________

______________________________________________________________________

______________________________________________________________________

**Part B** (Question 9)
(15 marks)

---

*Your response will be assessed on how well you:*
- *demonstrate understanding of the stimulus text*
- *write text that is appropriate and relevant to context, purpose, and audience*
- *structure and sequence information and ideas*
- *manipulate language structures and vocabulary in Khmer.*

---

9. Read the text and then answer the question in approximately 150 words in KHMER.

### នឿយមុនស្រណុកក្រោយ

នៅក្នុងអំឡុងដើមឆ្នាំ១៩៨០ មានចំនួនជនភៀសខ្លួនជាច្រើនគ្រួសារបានមករស់នៅក្នុងប្រទេសអូស្ត្រាលី។ គេទាំងឡាយមកពីប្រទេសមួយដែលគេមិនធ្លាប់បានទទួលប្រាក់ជំនួយពីរាជរដ្ឋាភិបាលនៅពេលគេទាំងនោះមិនមានការងារធ្វើទេ។ ដូច្នេះហើយ ក្នុងរយៈពេលដែលគេទាំងឡាយកំពុងមានការងារធ្វើ គេត្រូវតែធ្វើការយ៉ាងលំបាកវេទនា ដើម្បីខំសន្សំប្រាក់យ៉ាងខ្លាំងបំផុតដែលគេអាចធ្វើទៅបានព្រោះដោយសារតែភាពមិនច្បាស់លាស់ដែលគេត្រូវប្រឈមនៅអនាគត។ គេទាំងឡាយនៅតែបន្តធ្វើរបៀបនេះនៅប្រទេសអូស្ត្រាលី។ ឥឡូវណេះភាគច្រើនគេទាំងឡាយមានជីវភាពធូរធារគ្រាន់បើ។

សាមសិបឆ្នាំក្រោយមក កូនចៅរបស់គេទាំងនោះភាគច្រើនបានបញ្ចប់ការសិក្សារបស់ខ្លួនមានការងារធ្វើ និងបានទទួលប្រាក់ចំណូលច្រើនណាស់បើធៀបទៅនឹងប្រាក់ចំណូលរបស់មាតាបិតាគេកាលរស់នៅប្រទេសកម្ពុជា។ ជាការគួរអោយសោកស្តាយដែលក្រោយពីបានធ្វើការជាច្រើនឆ្នាំមកកូនចៅរបស់គេច្រើនណាស់មិនសន្សំប្រាក់បានច្រើនទេ។ កូនចៅទាំងនោះបានខ្ជះខ្ជាយប្រាស់កាសទៅលើរបស់របរប្រើប្រាស់ និងការសប្បាយរីករាយ។

មាតាបិតាព្រួយបារម្ភថាកូនចៅរបស់គេមិនរវល់គិតគូអំពីអនាគតសោះ។

QUESTION

You have read this article written by a concerned parent in the Angkor Thom community newspaper and decide to respond. Write a letter to the editor of the newspaper, responding to the issues raised in the article.

អ្នកបានអានអត្ថបទចុះផ្សាយនេះដែលសរសេរដោយមាតាបិតាដែលបារម្ភ ក្នុងសារពត៌មានសហគមន៍អង្គរធំ ហើយសម្រេចចិត្តថានឹងឆ្លើយតបទៅវិញ។ ចូរសរសេរសំបុត្រមួយផ្ញើទៅចាងហ្វាងនិពន្ធនៃសារពត៌មានអង្គរធំដើម្បីឆ្លើយតបទៅនឹងបញ្ហាដែលបានលើកឡើងក្នុងអត្ថបទនោះ។

*You may remove this page from the booklet by tearing along the perforations so that you will have the information in front of you for easy reference.*

You may make notes on this page.

This page is intentionally blank

Question 9

**End of Section 2**

Student/Registration Number | | | | | | | | | | | Centre Number | | | | | | |

# 2020 PUBLIC EXAMINATION

# Khmer

## Continuers Level

### Section 3: Writing in Khmer (20 marks)

**Instructions to Students**

1. Allow approximately 40 minutes for Section 3.
2. Write your answer to a question from Section 3 in this booklet using black or blue pen. Space is provided for you to make notes.
3. You must answer ONE question in KHMER.
4. Write your student/registration number and the centre number (if required) on the front cover of this booklet.
5. All question booklets will be collected at the end of the examination.

© SACE Board of South Australia 2020

**Section 3** (Questions 10 and 11)
(20 marks)

---

*Your response will be assessed on how well you:*

- *demonstrate depth of treatment of information, ideas and/or opinions*
- *write text that is appropriate and relevant to context, purpose, and audience*
- *structure and sequence information and ideas*
- *manipulate language structures and vocabulary in Khmer.*

---

Answer ONE question from this section in approximately 250 words in KHMER.

10. Write an article for your community magazine, comparing and evaluating the lifestyle of youth in Cambodia and youth in Australia.

    ចូរអ្នកសរសេរអត្ថបទមួយសម្រាប់ចុះផ្សាយក្នុងព្រឹត្តិប័ត្រសហគមន៍របស់អ្នកដោយធ្វើការប្រៀបធៀប និងធ្វើការវិនិច្ឆ័យអំពីជីវភាពរបស់យុវជននៅប្រទេសកម្ពុជាទៅនឹងជីវភាពយុវជននៅប្រទេសអូស្ត្រាលី។

11. To celebrate multicultural week, your community is publishing a book about the contribution of Khmer people to Australia. Each member of your Khmer class at school has been asked to write the profile of a Khmer person who they believe should be included in the book. Write a profile.

    ដើម្បីចូលរួមអបអរសាទរក្នុងសប្តាហ៍ពហុវប្បធម៌ សហគមន៍របស់អ្នកបម្រុងនឹងបោះពុម្ពផ្សាយសៀវភៅមួយដោយដាក់បញ្ចូលនូវការចូលរួមចំណែករបស់ជនជាតិខ្មែរនៅប្រទេសអូស្ត្រាលី។ សមាជិកនីមួយៗនៃថ្នាក់ភាសាខ្មែរនៅសាលារៀនរបស់អ្នកត្រូវបានគេស្នើអោយសរសេររៀបរាប់អំពីប្រវត្តិរបស់ជនជាតិខ្មែរណាម្នាក់ដែលគេទាំងឡាយជឿថាគួរតែដាក់បញ្ចូលក្នុងសៀវភៅនោះ។ ចូរសរសេរជីវប្រវត្តិនោះ។

*You may remove this page from the booklet by tearing along the perforations so that you will have the information in front of you for easy reference.*

You may make notes on this page.

This page is intentionally blank

Question Number:



PLEASE TURN OVER

**End of Section 3**